**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

~~~~~~~

សាលាឧទ្ធរណ៍ភ្នំពេញ
~~~~~
សំណុំរឿងព្រហ្មទណ្ឌ
លេខៈ០៣
ចុះថ្ងៃទី០៨-០១-២០១៩
សាលដីកាលេខ០២ ក្រ៕ "ញ"
ចុះថ្ងៃទី១៥-០៦-២០២០

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាឧទ្ធរណ៍ភ្នំពេញ**

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គតុលាការ ដែលប្រកាសឲ្យប្រើតាមរាជក្រម លេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៤ ។

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩ ដោយមានសមាសភាពដូចខាងក្រោមៈ

**ក្រុមប្រឹក្សាជំនុំជម្រះ**

ឯកឧត្តម ... ជាប្រធានក្រុមប្រឹក្សា

លោកស្រី ... ជាចៅក្រមប្រឹក្សា

លោកស្រី ... ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក ...

**ក្រឡាបញ្ជីសវនាការ**

លោកស្រី ...

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ០៣ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ដែលមានៈ

១.ជនជាប់ចោទឈ្មោះ **លចរ** ហៅ ជា ភេទស្រី អាយុ២០ឆ្នាំ ជនជាតិខ្មែរ សាសនា ព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិមេសប្រច័ន្ទ ឃុំមេសប្រច័ន្ទ ស្រុកពារាំង ខេត្តព្រៃវែង ទីលំនៅមុនពេលឃាត់ខ្លួន នៅបន្ទប់ជួលក្នុងផ្ទះសំណាក់បឹងលាភ ភូមិទួលសំពៅ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ...(រស់) ម្តាយឈ្មោះ ...(រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។

-មានលោក ... ជាមេធាវីការពារ

២.ជនជាប់ចោទឈ្មោះ ***សវ*** ហៅ រាជ អាយុ៣០ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិពោធិ៍សាលា១ ឃុំព្រែកក្របៅ ស្រុកកងមាស ខេត្តកំពង់ចាម ទីលំនៅមុនពេលឃាត់ខ្លួន នៅបន្ទប់ជួលក្នុងផ្ទះសំណាក់បឹងលាភ ភូមិទួលសំពៅ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ ...(រស់) ម្តាយឈ្មោះ ... (រស់) ប្រពន្ធឈ្មោះ **លចរ** កូនគ្មាន ជានីតិជន ទោសពីមុនគ្មាន ។

-មានលោក ... និងលោក ... ជាមេធាវីការពារ

៣.ជនជាប់ចោទឈ្មោះ **របរ** ហៅ ម៉ាប់ ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមិនពិតប្រាកដ កន្លែងកំណើតនៅភូមិពោធិ៍សាលា១ ឃុំព្រែកក្របៅ ស្រុកកងមាស ខេត្តកំពង់ចាម ទីលំនៅមុនពេលឃាត់ខ្លួន នៅបន្ទប់ជួលក្នុងផ្ទះសំណាក់បឹងលាភ ភូមិទួលសំពៅ សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ ...(រស់) ម្តាយឈ្មោះ ...(រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។

-មានលោក ...ជាមេធាវីការពារ

ជាប់ចោទពីបទ៖ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

តាមសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ៖៦៧៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៨ ឈ្មោះ **សសវ** ប្តឹងឧទ្ធរណ៍នឹងសាលក្រមលេខ៧១៥ក្រ១១(យ១) ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

តាមសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ៖៦៧៦ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៨ លោកស្រី... ជាមេធាវីការពារសិទ្ធិឲ្យឈ្មោះ **សសវ** ឈ្មោះ **របរ** ហៅ ម៉ាប់ ប្តឹងឧទ្ធរណ៍នឹងសាលក្រមលេខ៧១៥ក្រ១១(យ១) ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល។

តាមសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ៖ ៦៨១ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ ឈ្មោះ **របរ** ហៅ ម៉ាប់ ប្តឹងឧទ្ធរណ៍នឹងសាលក្រមលេខ៧១៥ក្រ១១(យ១) ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

តាមសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ៖៧៣៧ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ ឈ្មោះ **លថរ** ប្តឹងឧទ្ធរណ៍នឹងសាលក្រមលេខ ៧១៥ក្រ១១(យ១) ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

## ៦រឿងហេតុមានដូចតទៅ៖

កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ នៅចំណុចរាជធានីភ្នំពេញ បានកើតមានករណី ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន មួយកើតឡើង ដែលអំពើនេះបង្កឡើងដោយជនជាប់ចោទ ១.ឈ្មោះ **ករន** ហៅ ហ៊ីម ភេទប្រុស អាយុ៣២ឆ្នាំ ២.ឈ្មោះ **សវ** ហៅ រាជ អាយុ៣០ឆ្នាំ ៣.ឈ្មោះ របរ ហៅ ម៉ាប់ ភេទប្រុស អាយុ២០ឆ្នាំ ៤.ឈ្មោះ **លថរ** ហៅ ដា ភេទស្រី អាយុ២០ឆ្នាំ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនផែកឆែរឃើញមានថ្នាំញៀន រួមទាំងជញ្ជីងសម្រេប់ថ្លឹងគ្រឿងញៀនចំនួន១។ នៅពេលឃាត់ខ្លួនជនជាប់ចោទខាងលើបានឆ្លើយសារភាព ថ្នាំញៀន គឺពួកខ្លួនទិញពីឈ្មោះ **ណ** ហៅ ខ្មៅ ភេទប្រុស និងឈ្មោះ **ត** រួចសមត្ថកិច្ចក៏បាន

កសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។ ចំពោះជនជាប់ចោទ ១.ឈ្មោះ **ករន** ហៅ ហ៊ឹម ភេទប្រុស អាយុ៣២ឆ្នាំ ២.ឈ្មោះ ***សវ*** ហៅ រាជ អាយុ៣០ឆ្នាំ ៣.ឈ្មោះ ***របរ*** ហៅ ម៉ាប់ ភេទប្រុស អាយុ២០ឆ្នាំ ៤.ឈ្មោះ **លថរ** ហៅ ដា ភេទស្រី អាយុ២០ឆ្នាំ ត្រូវបានសមត្ថកិច្ចពិនិត្យទឹកនោម ឃើញមានសារធាតុញៀន។

បានឃើញសាលក្រមលេខ៧១៥ក្រ១១(យ១) ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ មានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.ផ្តន្ទាទោសលើជនជាប់ចោទ៖

ក.ឈ្មោះ **ករន** ហៅ ហ៊ឹម ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ

ដាក់ពន្ធនាគារកំណត់ចំនួន ៥(ប្រាំ)ឆ្នាំ ។

ខ.ឈ្មោះ ***សសវ*** ហៅ រាជ ភេទប្រុស អាយុ៣០ឆ្នាំ ជនជាតិខ្មែរ

គ.ឈ្មោះ ***របរ*** ហៅ ម៉ាប់ ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ

ឃ.ឈ្មោះ **លថរ** ហៅ ដា ភេទស្រី អាយុ២០ឆ្នាំ ជនជាតិខ្មែរ

ដាក់ពន្ធនាគារកំណត់ចំនួន ៦(ប្រាំមួយ)ឆ្នាំ ។

ពីបទ៖ **ជួញដូរនិងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២.វត្ថុចាប់យកដែលត្រូវរឹបអូសមាន៖

១.ស្រោមសំបុត្រពណ៌សមានក្រាមថ្លាទម្ងន់២,៨១ក្រាម (ពីរក្បៀសប៉ែតសិបមួយក្រាម) ជារបស់ជនជាប់ចោទឈ្មោះ **ករន** ។

២.ស្រោមសំបុត្រពណ៌សមានក្រាមថ្លាទម្ងន់២៥,០៣ក្រាម (ម្ភៃប្រាំក្បៀសសូន្យបីក្រាម) ជារបស់ជនជាប់ចោទឈ្មោះ សសវ , ឈ្មោះ ***របរ*** និងឈ្មោះ **លថរ**។

៣.ទូរស័ព្ទ០៣គ្រឿង ម៉ាកហូវ៉ាយ (HUAWEI) និងពីរគ្រឿងទៀត ម៉ាកណូគាខ្មៅចុចពិលចំនួន០១គ្រឿង ពណ៌សចំនួន០១គ្រឿង។

៤.ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនចំនួន០១ ក្រដាសអាលុយមីញ៉ូមចំនួន០១ដុំតូច ដបសម្រាប់ជក់គ្រឿងញៀនចំនួន០៤ និងដែកកេះចំនួន០១។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនាថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ **ករន** ហៅ ហ៊ឹម ភេទប្រុស អាយុ៣២ឆ្នាំ, ឈ្មោះ ***សសវ*** ហៅ រាជ ភេទប្រុស អាយុ៣០ឆ្នាំ, ឈ្មោះ ***របរ*** ហៅ ម៉ាប់

ភេទប្រុស អាយុ២០ឆ្នាំ និងឈ្មោះ **លថរ** ហៅ ដា ចំពោះមុខមេធាវីកាឬពារសិទ្ធិឲ្យជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញរបាយការណ៍រឿងចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ។

បានឃើញសេចក្តីសន្និដ្ឋានចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ របស់មហាអយ្យការសាលាឧទ្ធរណ៍ ។

បានឃើញដីកាចាត់តាំងសមាសភាពក្រុមប្រឹក្សាជំនុំជម្រះលេខ៖ ៨៨ដកឧ១៩ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាអានរបាយករាណ៍

ឈ្មោះ **សសវ** ឆ្លើយថាខ្លួនមិនសុខចិត្តប្តឹងឧទ្ធរណ៍មកនេះ ព្រោះតែថ្ងៃកើតហេតុខ្លួនមិននៅផ្ទះទេ ពេលចូលមកឆែឆេរខ្លួន។ ខ្លួនមិនដឹងរឿងអ្វីទាំងអស់ ហើយខ្លួនមិននៅផ្ទះ និងមិនគេចដោយមិនបានប្រព្រឹត្ត សមត្ថកិច្ចអត់មានរកឃើញនៅនឹងខ្លួន ពេលនោះឈ្មោះ **ករន** យកមកមិនបានដឹងថាជាគ្រឿងញៀនទេ គេច្រកនឹងថង់ខ្មៅយកមកឈ្មោះ **លថរ** បានដឹង យកមកបន្ទប់ខ្លួនជួលនៅពេលខ្លួនមកពីខាងក្រៅវិញ ស្រាប់តែជួបហេតុការណ៍នេះតែម្តង។ ឈ្មោះ **ករន** គេចាប់បានហើយ បាននាំសមត្ថកិច្ចមកមាន ជញ្ជីងនៅក្នុងថង់ទាំងអស់នេះ ។ ខ្លួនពិតជាមិនបានប្រព្រឹត្តទេ ព្រោះរបស់មិនមែនជារបស់ខ្លួន គេយកមកទុក។ ពេលចាប់ខ្លួនៗមិនបាននៅកន្លែងកើតហេតុទេ ចៃដន្យមកដល់នៅផ្ទះសំណាក់តែម្តង ។ សំណូមពរលើកលែងការចោទប្រកាន់។

ឈ្មោះ **លថរ** ឆ្លើយថា ខ្លួននៅបន្ទប់ជួលជាមួយគ្នា ខ្លួនមិនសុខចិត្តប្តឹងឧទ្ធរណ៍មកនេះចង់ឲ្យតុលាការបន្ធូរបន្ថយទោស ដោយសារដាក់ទោសខ្លួនធ្ងន់ពេក ចំពោះជាគ្រឿងឈ្មោះ **ករន** យកមកទុកដាក់នៅក្នុងថង់ខ្មៅ ខ្លួនអត់បានដឹងផង ឈ្មោះ **ករន** ទើបតែស្គាល់គ្នា។ ខ្លួនអត់បានចែកចាយទេ ថង់ខ្មៅនេះឈ្មោះ **ករន** ផ្ញើ។ សំណូមពរតុលាការបន្ធូរបន្ថយទោស។

ឈ្មោះ **របរ** ឆ្លើយថា ខ្លួនមិនសុខចិត្តប្តឹងឧទ្ធរណ៍មកនេះ ដោយសារដាក់ទោសខ្លួនធ្ងន់ពេក ខ្លួនទើបមកពីខេត្តកំពង់ចាម មកលេងមិនដឹងរឿងអីទៃ ក៏ត្រូវគេចាប់ខ្លួន។ មកដល់ពេលព្រឹក ពេលល្ងាចគេចាប់ ខ្លួនធ្លាប់ប្រើគ្រឿងញៀន តែខ្លួនមិនដឹងរឿងអ្វីទេថាមកលេងភ្នំពេញត្រូវគេចាប់ខ្លួនតែម្តង។ សំណូមពរលើកលែងការចោទប្រកាន់ឲ្យខ្លួនផង ព្រោះខ្លួនមិនដឹងរឿងទេ ។

តំណាងមហាអយ្យការសន្និដ្ឋានថា ក្នុងសំណុំរឿងនេះជនជាប់ចោទមានចំនួនបួននាក់ តែត្រូវបានសាលាដំបូងធ្វើការជំនុំជម្រះតាមសាលក្រមលេខ៧១៥ក្រ១១(យ១) ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដោយផ្តន្ទាទោសម្នាក់ៗ៦ឆ្នាំ ដោយសារតែគ្រឿងញៀនមានចំនួនច្រើន ឃើញថា

ការផ្តន្ទាទោសនេះស្របតាមបញ្ញត្តិច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ហើយសូមជូនក្រុមប្រឹក្សាពិនិត្យ និងសម្រេចចុះ។

លោក ... ធ្វើសេចក្តីសន្និដ្ឋានការពារដូចតទៅ៖ កូនក្តីខ្លួនឈ្មោះ ***សសរ*** បានបញ្ជាក់ថា ការចុះបង្ក្រាបរបស់សមត្ថកិច្ចឃើញគ្រឿងញៀននេះ គាត់មិនបានដឹងទេ គាត់នៅខាងក្រៅឈ្មោះ **ករន** ជាអ្នកដែលត្រូវសមត្ថកិច្ចចាប់នៅផ្លូវរថភ្លើង គាត់សារភាពហើយសមត្ថកិច្ចចាប់តាមការឆ្លើយរបស់ **ករន** រួចមកឆែកឆេរបន្ទប់ជួលរបស់កូនក្តីខ្លួនៗ មិនបានដឹងរឿងគ្រឿងញៀន ទើបពេលមកដល់ឃើញសមត្ថកិច្ចហើយមិនរត់ ផ្ទះសំណាក់មិនមានកាមេរ៉ាសុវត្ថិភាព តែមិនបានបើកមើលហើយចាប់កូនក្តីខ្លួនតាមការឆ្លើយរបស់ឈ្មោះ **ករន** ចម្លើយអយ្យការ នៅថៅក្រមស៊ើបសួរ កូនក្តីខ្លួនបានឆ្លើយបដិសេធការចោទប្រកាន់ និងការសម្រេចសេចក្តីរបស់សាលាដំបូងមកធ្វើទៅលើការសង្ស័យដែលផ្ទុយពីច្បាប់ថ្លែងថា រាល់ការសង្ស័យឲ្យប្រយោជន៍ជនជាប់ចោទតាមមាត្រា ៣៥១ នៃក្រមព្រហ្មទណ្ឌមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ ប្រសិនបើកូនក្តីខ្លួនធ្វើត្រូវទទួលខុសត្រូវតាមច្បាប់ តែគាត់អត់បានធ្វើ សំណូមពរឲ្យកូនក្តីខ្លួនរួចពីបទចោទ។

លោក ... ធ្វើសេចក្តីសន្និដ្ឋានបន្ថែមថា សូមបញ្ជាក់លើការសន្និដ្ឋាន ដោយឯកភាពលើសេចក្តីសន្និដ្ឋានរបស់លោក...សូមបន្ថែមថា ការផ្តន្ទាទោសរបស់សាលាដំបូងរួចមកនេះធ្វើការសម្រេចដោយផ្អែកលើការសង្ស័យដោយអង្គហេតុមិនមានភាពច្បាស់លាស់តាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ វិមតិសង្ស័យបានជាប្រយោជន៍ជនជាប់ចោទឈ្មោះ ***សសរ*** ។

លោក ...ធ្វើសេចក្តីសន្និដ្ឋានដូចតទៅ ពាក់ព័ន្ធនឹងអង្គហេតុនេះ តុលាការចោទប្រកាន់លើកូនក្តីខ្លួនពីបទជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ចំពោះ៖

-ឈ្មោះ **លថរ** បានបញ្ជាក់ហើយថា គាត់អត់បានដឹងរឿងថ្នាំញៀននោះទេ គ្រឿងញៀនក្នុងថង់ខ្មៅជារបស់ឈ្មោះ **ករន** ផ្ញើ ហើយពេលសមត្ថកិច្ចចុះឆែកឆេរក្នុងបន្ទប់ជួលផ្ទះសំណាក់បឹងលាភ ក្រោយពីការចាប់ឈ្មោះ **ករន** នោះគឺជារបស់ឈ្មោះ **ករន** មិនមែនជារបស់កូនក្តីខ្ញុំទេ គាត់ប្តឹងឧទ្ធរណ៍មកនេះសុំឲ្យតុលាការបន្ធូរបន្ថយទោសឲ្យគាត់។

-ឈ្មោះ ***របរ*** បានបញ្ជាក់ហើយថា គាត់មកលេងមិត្តភក្តិគាត់នៅភ្នំពេញពេលព្រឹក ពេលល្ងាចត្រូវសមត្ថកិច្ចចាប់ខ្លួនតែម្តង គាត់បានបដិសេធមិនទទួលស្គាល់ទេតាំងពីនៅសាលាដំបូង ហើយគាត់បានសារភាពហើយដែរថាគាត់ធ្លាប់ប្រើប្រាស់ សំណូមពរឲ្យក្រុមប្រឹក្សាបន្ធូរបន្ថយទោសដល់គាត់ ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឆ្លើយ និងស្នើសុំ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឲ្យជនជាប់ចោទ

ក្រោយពីបានពិនិត្យឯកសារដែលពាក់ព័ន្ធល្អិតល្អន់

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាឧទ្ធរណ៍**

**យល់ឃើញថា**

១.បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៥ ខែ៩ ឆ្នាំ២០១៨ របស់ឈ្មោះ ***សសរ*** និងលោកស្រី... ជាមេធាវីការពារឲ្យឈ្មោះ ***សសរ***, ឈ្មោះ ***របរ*** ហៅ ម៉ាប់ បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៧ ខែ៩ ឆ្នាំ២០១៨ និង បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២២ ខែ១០ ឆ្នាំ២០១៨ របស់ឈ្មោះ ***លថរ*** ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបានយោងតាមមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ ***សសរ*** នាពេលសវនាការសាលាឧទ្ធរណ៍បានបញ្ជាក់ថា ខ្លួនមិនសុខចិត្តប្តឹងឧទ្ធរណ៍មកនេះ ព្រោះតែថ្ងៃកើតហេតុខ្លួនមិននៅផ្ទះទេ ពេលចូលមកឆែឆេរខ្លួន។ ខ្លួនមិនដឹងរឿងអ្វីទាំងអស់ ហើយខ្លួនមិននៅផ្ទះ និងមិនគេចដោយមិនបានប្រព្រឹត្ត សមត្ថកិច្ចអត់មានរកឃើញនៅនឹងខ្លួនពេលនោះឈ្មោះ ***ករន*** យកមកមិនបានដឹងថាជាគ្រឿងញៀនទេ គេច្រកនឹងថង់ខ្មៅយកមក ឈ្មោះ ***លថរ*** បានដឹង យកមកបន្ទប់ខ្លួនជួលនៅពេលខ្លួនមកពីខាងក្រៅវិញ ស្រាប់តែជួបហេតុការណ៍នេះតែម្តង។ ឈ្មោះ ***ករន*** គេចាប់បានហើយ បាននាំសមត្ថកិច្ចមកមាន ជញ្ជីងនៅក្នុងថង់ទាំងអស់នេះ។ ខ្លួនពិតជាមិនបានប្រព្រឹត្តទេ ព្រោះរបស់មិនមែនជារបស់ខ្លួន គេយកមកទុក។ ពេលចាប់ខ្លួនៗមិនបាននៅកន្លែងកើតហេតុទេ ចៃដន្យមកដល់នៅផ្ទះសំណាក់តែម្តង។ សំណូមពរលើកលែងការចោទប្រកាន់។

៣.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ ***របរ*** នាពេលសវនាការសាលាឧទ្ធរណ៍បានបញ្ជាក់ថា ខ្លួនមិនសុខចិត្តប្តឹងឧទ្ធរណ៍មកនេះ ដោយសារដាក់ទោសខ្លួនធ្ងន់ពេក ខ្លួនទើបមកពីខេត្តកំពង់ចាម មកលេងមិនដឹងរឿងអីទេ ក៏ត្រូវគេចាប់ខ្លួន។ មកដល់ពេលព្រឹក ពេលល្ងាចគេចាប់ ខ្លួនធ្លាប់ប្រើគ្រឿងញៀន តែខ្លួនមិនដឹងរឿងអ្វីទេថាមកលេងភ្នំពេញត្រូវគេចាប់ខ្លួនតែម្តង។ សំណូមពរលើកលែងការចោទប្រកាន់ឲ្យខ្លួនផង ព្រោះខ្លួនមិនដឹងរឿងទេ ។

៤.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ ***លថរ*** នាពេលសវនាការសាលាឧទ្ធរណ៍បានបញ្ជាក់ថា ខ្លួននៅបន្ទប់ជួលជាមួយគ្នា ខ្លួនមិនសុខចិត្តប្តឹងឧទ្ធរណ៍មកនេះចង់ឲ្យតុលាការបន្ធូរបន្ថយទោស ដោយសារដាក់ទោសខ្លួនធ្ងន់ពេក ចំពោះជាគ្រឿងឈ្មោះ ***ករន*** យកមកទុកដាក់នៅក្នុងថង់ខ្មៅ ខ្លួនអត់បានដឹងផង ឈ្មោះ ***ករន*** ទើបតែស្គាល់គ្នា។ ខ្លួនអត់បានចែកចាយទេ ថង់ខ្មៅនេះឈ្មោះ ***ករន*** ផ្ញើ។ សំណូមពរតុលាការបន្ធូរបន្ថយទោស។

៥.តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ក្នុងសំណូមរឿងនេះជនជាប់ចោទមានគ្នាបួននាក់តែត្រូវបានសាលាដំបូងជំនុំជម្រះតាមសាលក្រមលេខ៧១៥ក្រ១១(យ១) ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដោយផ្តន្ទាទោសម្នាក់ៗ៦ឆ្នាំ ដោយសារតែគ្រឿងញៀនមានចំនួនច្រើន ឃើញថា

ការផ្តន្ទាទោសនេះស្របតាមបញ្ញត្តិច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ហើយសូមជូនក្រុមប្រឹក្សាពិនិត្យ និងសម្រេចចុះ។

៦.លោក...ជាមេធាវីការពារឲ្យជនជាប់ចោទឈ្មោះ ***សសវ*** បានធ្វើសេចក្តីសន្និដ្ឋានការពារថា កូនក្តីខ្លួនឈ្មោះ ***សសវ*** បានបញ្ជាក់ថា ការចុះបង្ក្រាបរបស់សមត្ថកិច្ចឃើញគ្រឿងញៀននេះ គាត់មិនបានដឹងទេ គាត់នៅខាងក្រៅឈ្មោះ **ករន** ជាអ្នកដែលត្រូវសមត្ថកិច្ចចាប់នៅផ្លូវរថភ្លើង គាត់សារភាពហើយសមត្ថកិច្ចចាប់តាមការឆ្លើយរបស់ **ករន** រួចមកឆែកឆេរបន្ទប់ជួលរបស់កូនក្តីខ្លួនៗ មិនបានដឹងរឿងគ្រឿងញៀន ទើបពេលមកដល់ឃើញសមត្ថកិច្ចហើយមិនរត់ ផ្ទះសំណាក់មិនមានកាមេរ៉ាសុវត្ថិភាព តែមិនបានបើកមើលហើយចាប់កូនក្តីខ្លួនតាមការឆ្លើយរបស់ឈ្មោះ **ករន** ចម្លើយអយ្យការ នៅចៅក្រមស៊ើបសួរ កូនក្តីខ្លួនបានឆ្លើយបដិសេធការចោទប្រកាន់ និងការសម្រេចសេចក្តីរបស់សាលាដំបូងមកធ្វើទៅលើការសង្ស័យដែលផ្ទុយពីច្បាប់ថ្លែងថា រាល់ការសង្ស័យឲ្យប្រយោជន៍ជនជាប់ចោទតាមមាត្រា៣៥១នៃក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ ប្រសិនបើកូនក្តីខ្លួនធ្វើត្រូវទទួលខុសត្រូវតាមច្បាប់ តែគាត់អត់បានធ្វើ សំណូមពរឲ្យកូនក្តីខ្លួនរួចពីបទចោទ។

៧.លោក ... ជាមេធាវីការពារឲ្យជនជាប់ចោទឈ្មោះ ***របរ*** និងឈ្មោះ ***លថរ*** បានធ្វើសេចក្តីសន្និដ្ឋានការពារថា ពាក់ព័ន្ធនឹងអង្គហេតុនេះ តុលាការចោទប្រកាន់លើកូនក្តីខ្លួនពីបទជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនចំពោះ៖

-ឈ្មោះ ***លថរ*** បានបញ្ជាក់ហើយថា គាត់អត់បានដឹងរឿងថ្នាំញៀននោះទេ គ្រឿងញៀនក្នុងថង់ខ្មៅជារបស់ឈ្មោះ **ករន** ផ្ញើ ហើយពេលសមត្ថកិច្ចចុះឆែកឆេរក្នុងបន្ទប់ជួលផ្ទះសំណាក់បឹងលាភ ក្រោយពីការចាប់ឈ្មោះ **ករន** នោះគឺជារបស់ឈ្មោះ **ករន** មិនមែនជារបស់កូនក្តីខ្ញុំទេ គាត់ប្តឹងឧទ្ធរណ៍មកនេះសុំឲ្យតុលាការបន្ធូរបន្ថយទោសឲ្យគាត់ ។

-ឈ្មោះ ***របរ*** បានបញ្ជាក់ហើយថា គាត់មកលេងមិត្តភក្តិគាត់នៅភ្នំពេញពេលព្រឹក ពេលល្ងាចត្រូវសមត្ថកិច្ចចាប់ខ្លួនតែម្តង គាត់បានបដិសេធមិនទទួលស្គាល់ទេតាំងពីនៅសាលាដំបូង ហើយគាត់បានសារភាពហើយដែរថាគាត់ធ្លាប់ប្រើប្រាស់ សំណូមពរឲ្យក្រុមប្រឹក្សាបន្ធូរបន្ថយទោសដល់គាត់។

៨.ជនជាប់ចោទឈ្មោះ ***សសវ***, ឈ្មោះ ***របរ*** និងឈ្មោះ ***លថរ*** ត្រូវបានឃាត់ខ្លួនក្នុងករណីបទល្មើសជាក់ស្តែង ដោយដកហូតវត្ថុតាងគ្រឿងញៀនទម្ងន់២៥,០៣ក្រាម រួមទាំងជញ្ជីងថ្លឹងចំនួន០១គ្រឿងទៀតផង។

៩.តាមលទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ ១៣៥៧០/១៨ អពអជបគញ ចុះថ្ងៃទី០៦ ខែ៤ ឆ្នាំ២០១៨ របស់មន្ទីរពិសោធន៍នៃក្រសួងមហាផ្ទៃបានបញ្ជាក់ថា ជាប្រភេទមេតាំហ្វេតាមីនដែលមានបរិមាណធាតុសុទ្ធ៧៨,៩៩% ដូចនេះបរិមាណធាតុសុទ្ធនៃគ្រឿងញៀនដែលជនជាប់ចោទទាំងបីនាក់ខាងលើបានប្រព្រឹត្តគឺ ២៥,០៣x៧៨,៩៩/១០០=១៩,៧៧ក្រាម ។

១០.មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ***សសវ***, ឈ្មោះ ***របរ*** និងឈ្មោះ ***លថរ*** ពីបទះ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១១.ជនជាប់ចោទទាំងបីនាក់ បានសំណូមពរក្រុមប្រឹក្សានឹងលើកយកមកបន្ធូរបន្ថយទោសឲ្យជនជាប់ចោទកម្រិតអប្បបរមានៃទោសដោយហេតុថា ជនជាប់ចោទទើបតែបានប្រព្រឹត្តបទល្មើសជាលើកដំបូង ហើយបរិមាណគ្រឿងញៀនសមាមាត្រទៅនឹងកម្រិតនៃទណ្ឌកម្មអប្បបរមា និងម្យ៉ាងទៀតដើម្បីទុកឱកាសឲ្យជនជាប់ចោទបានកែប្រែខ្លួនជាពលរដ្ឋល្អក្នុងសង្គមឡើងវិញ។

១២.រឿងក្តីនេះត្រូវបានសាលាដំបូងរាជធានីភ្នំពេញ ធ្វើការអង្កេត និងលើកយកសំអាងហេតុមកបញ្ជាក់ត្រឹមត្រូវតាមច្បាប់ហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនោះ ដូចនេះសាលាឧទ្ធរណ៍មិនចាំបាច់លើកយកសំអាងហេតុនេះមកបញ្ជាក់ជាថ្មីទៀតទេ ។

១៣.សាលក្រមព្រហ្មទណ្ឌលេខៈ៧១៥ "ឃ១" ក្រ||ចុះថ្ងៃទី២១ ខែ៩ ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និងគតិច្បាប់ហើយគប្បីតម្កល់ទុកជាបានការ លើកលែងតែចំណុចទី១ ក.ខ.ឃ ត្រូវសម្រេចឡើងវិញតាមការយល់ឃើញខាងលើ។

## ហេតុដូច្នេះ-វិនិច្ឆ័យសេចក្តី

១.ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៥ ខែ៩ ឆ្នាំ២០១៨ របស់ឈ្មោះ ***សសវ*** និងលោកស្រី... ជាមេធាវីការពារឲ្យឈ្មោះ ***សសវ***, ឈ្មោះ ***របរ*** ហៅ ម៉ាប់ បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៧ ខែ៩ ឆ្នាំ២០១៨ របស់ឈ្មោះ ***របរ*** ហៅម៉ាប់ និងបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២២ ខែ១០ ឆ្នាំ២០១៨ របស់ឈ្មោះ***លថរ*** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ៧១៥ "ឃ១" ក្រ||ចុះថ្ងៃទី២១ ខែ៩ ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែចំណុចទី១ ក.ខ.ឃ ត្រង់ចំណុច "ផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៦ឆ្នាំ" ត្រូវកែប្រែមកជា "ផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៥ឆ្នាំវិញ" ។

៣.បន្តឃុំខ្លួនលើជនជាប់ចោទឈ្មោះ ***សសវ***, ឈ្មោះ ***របរ*** និងឈ្មោះ ***លថរ*** ។

៤.សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ ។

ទុកសិទ្ធិឲ្យប្តឹងសាទុក្ខតាមកំណត់ច្បាប់។

**ក្រឡាបញ្ជី** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សា**

...................................